# វគ្គ អ្នកទោសទាំងមិនដឹងថាបានខុសអ្វី

តំណក់ភ្លៀងបាននឹងកំពុងវាយលុកតាមចង្អូរបង្អួច នៃកន្លែងលាក់ខ្លួនរបស់ស៊ីណាន។ នេះជាប្រភេទផ្ទះល្វែងមួយនៅដាច់ស្រយាលឆ្ងាយពីទីក្រុង។

ពិតានត្រូវបានតុបតែងយ៉ាងល្អិតល្អន់បង្កប់ភ្លើងភ្លឺច្បាស់ ប៉ុន្តែអារម្មណ៍នៃការជាប់បង្ខាំងនិងភាពឯកោគឺមិនអាចធ្វើឱ្យនារីម្នាក់មើលឃើញទិដ្ឋភាពស្អាតនៃបន្ទប់នេះឡើយ។

សំឡេងខ្យល់ព្យុះនៅខាងក្រៅផ្ទុយនឹងបរិយាកាសតានតឹងនៅខាងក្នុង។

ដារីន ដែលឥឡូវនេះជាចំណាប់នៅកន្លែងលាក់ខ្លួនរបស់ស៊ីណាន ត្រូវបានគេបង្ខាំងទុកក្នុងបន្ទប់ដែលមានគ្រឿងសង្ហារិមមួយគ្រប់ និងមានភាពឆើតឆាយ ប៉ុន្តែបើធៀបនឹងភាពកក់ក្តៅក្នុងជីវិតរស់នៅរបស់នាងពីមុនមក គឺមេឃនិងដី។

ដារីនមិនដឹងទេថា អ្វីទៅជាបំណងចិត្តពិតរបស់ស៊ីណាន ដែលជាបុគ្គលិកម្នាក់នៅក្រុមហ៊ុនប៉ានាង បានផ្លាស់ប្តូរមកជាមនុស្សចាប់ជម្រិត ពោរពេញទៅដោយការខឹងសម្បា។

ដារីនក្រោកតិចៗ សម្លឹងជុំវិញ។

«យើងនៅជាប់ក្នុងដៃមនុស្សពាលម្តេចដេកលក់ទៅកើត?»

ស្រីគិតហើយស្ទុះស្ទាក្រោកមក អង្គុយនៅលើគែមកៅអី សម្លឹងមើលភ្លៀងធ្លាក់តាមបង្អួច។ តំណក់នីមួយៗបានដើរតាមមាគ៌ារបស់ធម្មជាតិឆ្លុះបញ្ចាំងពីភាពយឺតយ៉ាវនៃចិត្តគំនិតរបស់នាង ដែលបែកខ្ញែក ច្របូកច្របល់ អស់សង្ឃឹម។

ខ្យល់ព្យុះនៅខាងក្រៅបានបក់បោកដោយកំហឹងនៅតាមជញ្ជាំងកញ្ចក់ ហាក់ដូចជាធម្មជាតិខ្លួនឯងកំពុងឆ្លុះបញ្ចាំងពីភាពរឹករវដែលនាងមិនអាចបង្ហាញបាន។

ផ្ទុយទៅវិញ ភាពស្ងៀមស្ងាត់រវាងនាងនិងស៊ីណានមានសភាពអាចថាចប់ដង្ហើម។ ភាពឆើតឆាយនៃបន្ទប់ចំអកឱ្យនាង។ គ្រឿងសង្ហារិមរលោង ផ្ទៃប៉ូលានិងក្រណាត់ទន់ៗមិនអាចជំនួសបាននូវភាពកក់ក្តៅនៃអតីតជីវិតរបស់នាង ពោលគឺការលួងលោមដ៏ទន់ភ្លន់នៃគ្រួសារនាង សុវត្ថិភាពនៃការការពាររបស់ឪពុកនាង។ ឥឡូវនេះ អ្វីៗទាំងនោះមានអារម្មណ៍ថាជាកម្មសិទ្ធិរបស់ពិភពលោកមួយផ្សេងទៀតទាំងស្រុង។ នៅទីនេះ ភាពប្រណីតគឺជាគុក ហើយបុរសដែលធ្លាប់ធ្វើការឱ្យឪពុក

នាង ជាអ្នកចាប់នាង។ គិតឡើងវិញនូវរឿងទាំងអស់ ស្វាងចេញពីភាពសើងម៉ើងហើយ បេះដូងដាវីនបានលោតញាប់។ នាងព្យាយាមយល់គ្រប់យ៉ាងដើម្បីដោះបញ្ហាតែនៅមិនយល់ជាដដែល។

ស៊ីណាន ជានិយោជិតម្នាក់មានឋានៈខ្ពស់ មានទេពកោសល្យ និងស្នាដៃគួរឱ្យទុកចិត្ត គោរពឥឡូវនេះគេប្តូរជាមនុស្សដែលមានការខឹងសម្បា ហើយដែលនាងមិនអាចយល់បានពេញលេញថាព្រោះ ហេតុអ្វី? ហេតុអ្វីបានជាគេចាប់នាងមក? គេចង់បានលុយឬគេមានគំនិតប្រឆាំងនឹងគ្រួសារ? ប្រឆាំងនឹងនាង? ភ្នែករបស់នាងសម្លឹងឆ្ពោះទៅកាន់ទ្វារដែលតែងតែបិទជាប់ បង្ខាំងនាងនៅកន្លែងនេះ។

ស្រីបិទភ្នែកទុកឱ្យបណ្តាវិនាទីកន្លងទៅ តែពេលវេលាយឺតណាស់ ហើយដោយសង្កត់លើទ្រូងរបស់នាងដូចជាទម្ងន់នៃកំហឹងរបស់ស៊ីណានដែលមិនអាចដោះស្រាយបាន។

«ចាំមើល ប៉ាម៉ាក់នាង កម្សត់យ៉ាងណាពេលបាត់ព្រះនាងពីផ្ទះមួយយប់ទៅហើយ!»

គេនិយាយពេលបង្ហាញខ្លួននៅមាត់ទ្វារធ្វើឱ្យនាងភ្ញាក់ដាក់ជើងចុះមកដល់ឥដ្ឋ។ មនុស្សប្រុសមាឌធំដែលនាងធ្លាប់ចួបម្តងម្កាលមិនទាំងបាននិយាយគ្នាសោះ ពេលនេះមកក្លាយជាតួអង្គបង្ខាំងនាង?

នាងចង់សួរនាំដែរ ប៉ុន្តែហាមិនរួចព្រោះគ្រប់យ៉ាងមិនច្បាស់លាស់។

«យើងមានរឿងអីជាមួយគ្នា?» នាងស្រដីតិចៗពេលមនុស្សប្រុសដើរហួសទៅរកពិនិត្យដានភ្លៀងតាមបង្អួច។ គេនៅស្ងៀម គិតពេលនាងត្រូវនាងសួរដូច្នេះ។

មនុស្សដែលធ្លាប់ងក់ក្បាល ឱនលំទោនយ៉ាងគួរសមនៅក្នុងការិយាល័យឪពុកនាង ឥឡូវមើលទៅទុកនាងមិនស្មើ គេបែរខ្នងនិយាយ៖

«មានច្រើន!»

«ខ្ញុំមិនដែលធ្វើអីស៊ីណានទេ!»

ប្រុសងាកមកញញឹមឈឺៗ។ នាងស្ទើរតែមិនបាននិយាយអ្វីច្រើនតាមចិត្តដែលមានសន្ទុះទេព្រោះចាញ់ទឹកមុខដ៏មានគំនុំរបស់គេ។ នាងសម្លឹងគេ តែមិនហាអ្វីបានទៀតព្រោះចាញ់ប្រាប។ ភាពស្ងៀមស្ងាត់របស់ស្រីបានធ្វើឱ្យនាយញញឹមបន្ថែមនិងសម្លឹងនាងពីលើដល់ក្រោម ធ្វើឱ្យចិត្តដាវីន នាងរំជើបរំជួលលើសពីពាក្យដោយការបារម្ភនិងសង្ស័យ។

«ចង់ដឹងទេ?» គេសង្រ្គឹតធ្មេញហើយបន្ត «ជាតិនេះពួកអ្នកមានដូចនាងសងគ្រួសារយើងមិនអស់ទេ ម៉ែន ដាវីន!»

ដាវីន អង្គុយកកក្នុងភាពស្ងៀមស្ងាត់តែ បេះដូងរបស់នាងលោតញាប់ពេលមានអារម្មណ៍ថា មានវត្ថុមានរបស់ស៊ីណានរំកិលចូលមកក្បែរ។ គេមានទឹកមុខស្រអាប់ដោយគំនុំ ភ្នែកទាំងសងខាងមោទនៈ និងមិនអាចអានយល់បាន។

«មនុស្សល្អ គេមិនចាប់ស្រីទេ!»

នាងនិយាយតិចៗញ័រៗបណ្ដាលឱ្យខាងប្រុសបញ្ចេញស្នូរសំណើចបង្អួសយ៉ាងវែង។ គេបានធ្វើចលនាដោយស្ងប់ស្ងាត់ និងស្រាលស្ទើកមកពីមុខនាង កៀកគ្នាខ្លាំង។

ពោះរបស់នាងរមួលដោយការថប់បារម្ភ។

«ចេញឆ្ងាយៗពីខ្ញុំ!»

សំឡេងរបស់នាងគ្រាន់តែជាសូរខ្សឹបខ្សៀវ ប៉ុន្តែក្នុងបន្ទប់ស្ងាត់ មានអារម្មណ៍ថាឮខ្លាំងៗដូចជាការអង្វរ។ ឬភិតភ័យស្លន់របស់ក្មេងស្រីម្នាក់ទើបតែមានវ័យ១៨ឆ្នាំ។

«ខ្ញុំមិនដែលបានធ្វើអីយើងទេ!»

«តែប៉ានាងធ្វើ!» ស៊ីណានបានឈប់ជំទែងលើជើងទាំងពីរខ្ពស់ច្រង៉ាងរបស់គេ ពីមុខស្រីតូច។ នាងឱនមុខ មិនយំសោកទេប៉ុន្តែដាវីនតក់ស្លុត ស៊ីណានតាមដានដឹងដោយស្ងប់ស្ងាត់។

ការក្រឡេកមើលរបស់គេមកលើសរសៃសក់នាង មិនមែនដោយភាពសាហាវឃោរឃៅដែលនាងបាននឹងកំពុងគិតភ័យខ្លាចនោះទេ ប៉ុន្តែជាមួយនឹងអ្វីផ្សេង.....ការអន់ចិត្ត ការខកចិត្ត។

ប្រហែលជា....ពណ៌នាថា ឈឺចាប់ត្រូវជាង។

«គិតថាធ្វើពើ ក៏រួចខ្លួន?» សំឡេងរបស់ខាងប្រុសទម្លាក់មកទាប តាមរបៀបចរិតនឹងនរដែលគ្រប់គ្រងខ្លួនគេបាន ប៉ុន្តែមានគំនាបមួយសម្រាប់ដាវីន។

នាងឈ្ងោកគ្រវីក្បាលយ៉ាងញាប់ ដូចជាចង់ប្រាប់ថាមិនពាក់ព័ន្ធ មិនដឹងនិងមិនចង់ដឹង មិនចង់ជជែកអ្វីជាមួយស៊ីណានទៀតឡើយ។

«លែងខ្ញុំទៅ!»

«លែងទេតើ ពេលប៉ានាងស្លាប់!»

«ប៉ាខ្ញុំ?»

នាងងើបមុខមកដោយច្របូកច្របល់ ប៉ុន្តែអារម្មណ៍ភ័យខ្លាចបានកប់ក្នុងទ្រូងរបស់នាងច្រើនជាង គឺពេលនេះ នាងខ្លាចគេធ្វើអីប៉ានាង។

ស៊ីណានងក់ក្បាលតិចៗ ជាមួយទឹកមុខគ្មានមនោសញ្ចេតនា។

ទើបតែចាប់អារម្មណ៍ភាពរឹងមាំនិងកាចមានះរបស់ស៊ីណាន ហាក់មិនដូចបុរសដែលនាងបានចងចាំពីការិយាល័យរបស់ប៉ានាងពីមុនទៀតនោះទេ។

ឥឡូវនេះ គេមើលទៅមានបេះដូងត្រជាក់គ្មានមនោសញ្ចេតនា និងអាចពិបាកលើសពីនេះ តែគេហាក់ដូចជាកំពុងគ្រោងអ្វីមួយផ្សេងដែលជ្រៅជាងនេះទៅកាន់គ្រួសារនាង។

«លោកឆ្កួតហើយ! ប៉ាម៉ាក់ខ្ញុំជាមនុស្សល្អ!»

ស្នូរសំណើចបានផ្ទុះនៅក្រោមការក្រពាត់ដៃរបស់ខាងប្រុស។ ស៊ីណានសើចអស់ចិត្តទុកឱ្យនាងឡិងឡង់ ហើយទើបគេនិយាយសង្កត់ពាក្យមួយៈ

«មនុស្សចង្រៃបំផុត ក៏យល់ថាខ្លួនឯងជាមនុស្សល្អដែរ ហើយទៅកុហកកូនខ្លួនឯងបានទៀត?»

នាងធីងើនឹងពាក្យទាំងនេះ។ ធីតាអភិជនមិនដែលធ្លាប់ឮឬប្រើពាក្យអស់នេះទេពីមុនមក។ នាងក្រោកភ្លាមមកប្រឈមនឹងមនុស្សនេះ ហើយដារីននិយាយឡើងទាំងសំឡេងតឹងរឹងថាៈ

«ឈប់និយាយអាក្រក់មើលងាយថៅហ្វាយខ្លួនឯង!»

ញញឹមមិនដល់មួយដង្ហើមព្រោះស្ងើចភាពក្លាហានរបស់នាង ខាងប្រុសជះសម្ដីវិញបំបាត់ភាពឡូយឆាយរបស់នារីនេះៈ

«ប៉ានាង មិនមែនជាថៅហ្វាយទេ ជាឧក្រិដ្ឋជន!»

«មនុស្សច្រណែន!» នាងស្រែកហើយខាំមាត់សម្លក់គេ ច្រមុះសឹងប៉ះគ្នាព្រោះដារីនខឹងខ្លាំងនិងភ្លេចគ្រោះថ្នាក់ផងទាំងពួង។

«ច្រណែន ដែលប៉ានាងបានបំផ្លាញគ្រួសារខ្ញុំ? អ្ហះ?»

«ប៉ាខ្ញុំ?»

«ហាសហា! មនុស្សថ្លៃថ្នូរអើយ ភ្ញាក់ផ្អើលណាស់មែនទេ?»

គេនិយាយហើយសម្លឹងនាងស្រឹមទាំងមិនខ្ចីចង់វាចាអ្វីឈ្លោះនឹងមនុស្សស្រីច្រម៉ក់ដែលមិនដឹងអីថៃមទាំងចចេស។ ពួកអភិជនដូចនាង រមែងគិតថា អ្នកណាមករកយុត្តិធម៌គឺមកតែពីគេច្រណែនពួកនាងនិងគ្រួសារនាងទាំងអស់ ទាំងដែលការពិតអភិជនលោភលន់គ្មានព្រំដែនដូចជាប៉ានាងវិញទេ ដែលគួរតែត្រូវបានបកអាក្រាត។

គេបានមើលឪពុកខ្លួនដួលរលំមួយដំណាក់ៗ ខណៈដែលឪពុករបស់ដាវីនឡើងខ្ពស់ដោយប្រើការលេងល្បិចកេងបន្លំដ៏ថោកទាបលើមិត្តខ្លួនឯង។

ទ្រព្យសម្បត្តិនិងអំណាចរបស់គ្រួសារនាងសព្វថ្ងៃជាចំណែកប៉ារបស់គេ។

ដាវីនមានអារម្មណ៍ថា មានសេចក្ដីគុំកួនមួយយ៉ាងធ្ងន់ក្នុងពាក្យពេចន៍នានារបស់បុរសនេះ ប៉ុន្តែនាងមិនខ្វល់និងមិនគិតច្រើនឡើយថាប៉ានាងបានធ្វើអ្វីខ្លះទេ ព្រោះស៊ីណានជាឧក្រិដ្ឋជនចាប់នាងមកទាំងមិនសមហេតុផល។

«បំផ្លាញគ្រួសារខ្លួន? ពីពេលណា?» នាងសួរទាំងងក់ក្បាល ដកដង្ហើមចូលបំពង់កហត់គយូស។ មិនឃើញគេនេះឆ្លើយ នាងនិយាយការពារបន្ថែម «ប៉ារបស់ខ្ញុំ...មិនដែល»

ប្រុសនិយាយកាត់ត្រជាក់ល្ហឹមៈ

«១៧ឆ្នាំមុន មានកិច្ចព្រមព្រៀងមួយ!»

គេនៅស្ងៀមវិញ.....ខណៈសម្ដីម្ដាយគេបានលាន់មកវិញ។ «កូនឯងអាយុ៤ឆ្នាំ ក្មេងស្រីនោះ១ឆ្នាំ ប៉ាឯងបានសម្រេចចិត្តដណ្ដឹងនាងមកជាកូនប្រសារនិងប្រគល់ដីចម្ការជិត៨០០ហិកតាឱ្យគ្រួសារនោះធ្វើកសិឧស្សាហកម្មនិងចិញ្ចឹមគោយកទឹកដោះ! នៅពេលមិនយូរប៉ាឯងឈឺ គាត់ខ្វះលុយ! គាត់សម្រាកស្ងៀមគេបានកេងបន្លំលើកុងត្រាលេបយកហ៊ុនគ្រួសារយើង! គ្រួសារលោកម៉ែន ដា បានបានរុញប៉ាឯងឱ្យទ័ល ឈឺចាប់និងស្លាប់ ពួកវាបានបំផ្លាញគ្រួសារយើង ហើយគ្មាននរណាម្នាក់ខ្វល់ទេ គ្មាននរណាម្នាក់មើលរឿងនេះពីរដងទេ ព្រោះយើងក្រនិងគ្មានលុយរកផ្លូវច្បាប់!»។

ភ្នែករបស់ស៊ីណានមមីរតូច។ កូនស្រីត្រកូលនេះ គេគ្មានចង់បានមកជាប្រពន្ធមួយចុងក្រចកណាទេ ។ សំឡេងរបស់គេតបតមកនាងក្លាយជាពាក្យខ្សឹបខ្សៀវដ៏គ្រោះថ្នាក់ៈ

«ដំណើរជីវិតដ៏ល្អឥតខ្ចោះរបស់គ្រួសារនាង ឈានដល់ចុងបញ្ចប់ហើយ! ប៉ានាងនឹងជាប់គុក ហើយម្ដាយរបស់នាង ជំទាវមាលា នឹងរស់កំដរការឈឺចាប់!»

ដើមទ្រូងរបស់ដាវីនរឹតតែលោតដង្ហក់ដោយការជឿលើអ្វីដែលបុរសនេះនិយាយព្រោះនាងគិតថាគេនឹងធ្វើ។

«លោកហ៊ាន?»

សំឡេងនាងស្រែកឡើងស្រួយស្រិបលាយឡំជាមួយភាពវិលវល់មិនយល់អ្វី មានអារម្មណ៍ខុសៗប្រក្រតី និងគិតថាស៊ីណានមានកំហឹងព្រោះតែការយល់ច្រឡំអ្វីមួយ។

«ហ៊ាន?» គេសើចដាក់ភ្នែករលោងរបស់នាង ហើយនិយាយបន្ថែមព្រោះនាងគាំង៖ «ក្មេងប្រុសម្នាក់ដែលមានមរតកដីជិតមួយពាន់ហត្ថ បានធ្លាក់ខ្លួនដើរលាងចាននិងលាងបង្គន់គេតាំងពីអាយុ៩ឆ្នាំបានមានលុយរៀន! ប៉ាគេស្លាប់ម្ដាយគេពិការ នាងគិតថាស្អីទៀតទៅ ដែលវាមិនហ៊ានធ្វើអ្នកនាងតូច?»

ដូច្នេះនេះគឺជាការសងសឹក? នាងបានគិតពាក្យទាំងនេះ ទាំងដាវីនទ្រាំលេបការបារម្ភមួយយ៉ាងធ្ងន់មិនបញ្ចេញមកក្រៅទេ។

នាងខំមានះធ្វើរឹងប៉ឹង ងើយមុខជជែករកហេតុផល៖

«ហេតុអ្វីមនុស្សសង្គមនេះ ចូលចិត្តទម្លាក់បន្ទុកកម្មផល ភាពក្រលំបាករបស់ខ្លួនទៅលើអ្នកដ៏ទៃដែលគេបានល្អជាង? ធ្វើអ៊ីចឹងធ្វើអី? មនុស្សចិត្តចង្អៀត!»

កែវភ្នែកត្រជាក់ៗរបស់ស៊ីណានបានក្រឡេកមកចួបជាមួយកែវភ្នែកនាងមួយភ្លែតព្រោះនាងកំពុងសម្លឹងមកទទូចចង់បានចម្លើយ។ គេញាក់ស្មា មាត់និងច្រមុះកៀកគ្នា ប៉ុន្តែភាពតានតឹងរវាងពួកគេគឺខុសពីគ្នាធ្ងន់ ម្ខាងជើងមេឃម្នាក់។

«និយាយបានល្អ! អ្នកនាងតូច!» គេងក់ក្បាលឪដងដោយស្ងប់ស្ងាត់ «ប៉ុន្តែ ទុកពាក្យនេះសម្រាប់ខ្លួនឯងទេ! ពួកអ្នកមានដោយសារលួចគេ!»

ដាវីនខាំមាត់ ងក់ក្បាលតិចៗ។ មានអារម្មណ៍ថា ទម្ងន់នៃពាក្យរបស់គេធ្វើឱ្យនាងខឹងនិងចង់ឈ្នះ។ ស្រីវាចារអ៊ូៗ៖

«គ្រាន់បើណាស់ មនុស្សចង់សម្លុតស្រី!»

មានអារម្មណ៍ថា ផ្នែកខ្លះនៃរាងកាយរបស់នាងកំពុងតានតឹង។

«លែង!» នាងរើនឹងការក្រៀករឹតត្បិតរបស់គេ។

«ចង់ធ្វើអីខ្ញុំ?» សំណួរបានធ្លាក់ចេញ ពោរពេញទៅដោយការភ័យខ្លាចនិងមិនប្រាកដប្រជា ខណៈស៊ីណានក្រៀកនាងយ៉ាងមាំ ហើយឈប់ស្ងៀមមួយសន្ទុះ ឱ្យនាងឃើញមុខម៉ឹងម៉ាត់ក្នុងកំហឹងរបស់គេ មុនពេលគេប្រែមកជាស្រទន់និងបានចិត្ត។

«គិតថា ខ្ញុំធ្វើអីនាង អ្ហះ?» គេគ្រលាស់អណ្ដាត «ស្រីងាប់អស់ ក៏ខ្ញុំនឹងមិនឡើងជាមួយនាងដែរ ស្រីឆ្នាស....កូនស្រីមេចោរអន្ធពាល!» សំឡេងរបស់គេប៉ុន្មានម៉ាត់ចុងក្រោយនេះ មានសព្ទស្ងប់ល្អ តែធ្ងន់ល្មមឱ្យទឹកភ្នែកដារីនហូរខ្វាយ។

គេអាចដៀលនាង តែគេមិនអាចនិយាយមើលងាយប្រមាថប៉ានាងបែបនេះទេ។ នាងរើ ហើយរើទៀត ថែមចង់ទះតប់ក្ដិចមួលស៊ីណានមួយទំហឹងកូនស្រី។

«មនុស្សចង្រៃ!»

«ខ្ញុំអាចថា ចង្រៃមែនហើយសម្រាប់ពួកនាង ខ្ញុំនឹងនាំចង្រៃដល់គ្រួសារនាងពេលនេះដារីន! ប៉ុន្តែខ្ញុំមិនមែនជាបិសាចដូចប៉ានាងទេ យើងមិនដូចគ្នាទេអ្នកនាងមកពីគ្រួសារបាតដៃកខ្វក់!»

ស្មារបស់នាងធ្លាក់ចុះជាមួយនិងភាពអស់សង្ឃឹមដែលថាអាចនឹងបង្ខំឱ្យបុរសនេះ និយាយសុំទោសដែលបានប្រមាថគ្រួសារនាងនិងប៉ារបស់នាង។

លាយឡំជាមួយនឹងភាពភ័យខ្លាចដែលនៅតែតោងជាប់នៅខាងក្នុងទ្រូង ថាតើគេចង់ធ្វើអ្វីប៉ារបស់នាង។ ដារីនដាច់ចិត្តសួរ៖

«ចុះហេតុអី... ហេតុអ្វីបានជាយកខ្ញុំមកទីនេះ?»

«ដោយសារប៉ារបស់នាង ត្រូវការរៀនពីអារម្មណ៍បាត់បង់!»

អ្វីនាងចំហមាត់ ភ្នែកនាងរលោងទៅដោយជលនេត្រ។ ប្រុសបានចិត្តណាស់ គេញញឹមបញ្ឈឺ ហើយនិយាយបន្ថែមឡើងថា៖

«អ្វីមួយដែលមិនអាចជំនួសដោយលុយឬអំណាច! ប៉ានាងបានយកជីវិតឪពុកខ្ញុំតាមគ្រប់មធ្យោបាយ...ដើម្បីតែផលប្រយោជន៍ ហើយឥឡូវនេះខ្ញុំចង់ឱ្យប៉ានាងមានអារម្មណ៍ថា ទាំងនោះគ្មានន័យទេ ព្រោះជាមនុស្សគ្មានអំណាចអ្វីជួយ សូម្បីកូនស្រីខ្លួនឯង»

ដារីនមើលដៃនាងដែលទម្លាក់ចុះ គំនិតរបស់នាងវិលវល់។ ស៊ីណាន ដកដង្ហើមធំ ដើរថយក្រោយ ហើយរត់ដៃកាត់តាមក្លីសក់របស់គេ។

«នាងក៏ដូចគ្នា! រៀនរស់ក្នុងភាពអស់សង្ឃឹម និងគ្មានអ្នកណាទាំងអស់!»

ដារីននៅធ្មឹង មាត់ដូចលែងគ្រលាស់អណ្ដាតចេញ។

សម្លឹងមើលទៅគេ នាងមានការភ័យខ្លាចជាសម្ងាត់ថា មនុស្សឆ្កួតចិត្តដូចគេនេះតើនឹងធ្វើអ្វីខ្លះទៀតដែលនាងស្មានមិនដឹង។

ខ្យល់ព្យុះនៅខាងក្រៅបក់បោកខ្លាំងជាងព្យុះសង្សារនៅខាងក្នុងបន្ទប់នេះ។

## វគ្គ បាត់ខ្លួនអ្នកនាងតូច

អគ្គនាយកធនាគារកសិករ លោក ម៉ែន ដា កំពុងឈរនៅក្បែរកញ្ចក់ដ៏ធំទូលាយនៃការិយាល័យរបស់គាត់។ ដៃបុរសវ័យ៥០ឆ្នាំ ចាប់គែមតុឈើ ម៉ាក ម៉ាហូហ្កានីយ៉ាងតឹងណែន។

ផ្ទៃមេឃនៃទីក្រុងភ្នំពេញ បានលាតសន្ធឹងនៅពីមុខគាត់ក្នុងពន្លឺចិញ្ចាចនាពេលព្រលប់ ប៉ុន្តែអ្វីដែលគាត់បានឃើញគឺភាពងងឹត។

កំហឹងដ៏ជ្រៅមួយបានហូរកាត់បេះដូងជាសម្ងាត់ លាយឡំនឹងការភ័យខ្លាចដែលមិនធ្លាប់មានក្នុងឆាកជីវិតនេះ។ រយៈពេលជាច្រើនឆ្នាំ ទ្រូងរបស់គាត់ថប់បារម្ភលើនារីតូចតែមួយគត់ ដែលជាម្ចាស់បេះដូង គឺដាវីនដ៏ស្រស់ផូរផង់សមជាព្រះនាងក្នុងអាណាចក្រជំនួញមហាសាលរបស់គាត់ ពេលនេះនាងបាត់ខ្លួនមួយយប់ហើយ មិនឱ្យកំហឹងអគ្គនាយកប្រាក់ពាន់លានកើតមាន?

ម៉ែនដា ទើបតែចុះមកដល់ភ្នំពេញយ៉ាងបន្ទាន់។ ពេលកូនស្រីបាត់ខ្លួន គាត់នៅអាមេរិក....ឆ្ងាយសែនឆ្ងាយ។

«ម៉េចក៏គេយកកូនស្រីយើង ចេញពីក្រោមច្រមុះយើងបាន?»

គ្រប់គ្នានៅក្នុងបន្ទប់នៅស្ងៀមឈឹង លើកលែងតែនាឡិកាធំមួយនៅលើជញ្ជាំង រាល់វិនាទីមានការរំឭកដ៏ខ្លោចផ្សាថា កូនស្រីតែម្នាក់គត់របស់គាត់ឈ្មោះដាវីន កំពុងព្រាត់ទៅកន្លែងណាមួយ ត្រូវបានធ្វើបាបដោយនរណាម្នាក់ដែលជោគវាសនារបស់នាងនៅមិនទាន់ដឹងបាន។

តើអ្នកណាទៅដែលហ៊ានប្រលែងលេងបែបនេះជាមួយគាត់? អគ្គនាយក ម៉ែនដា ទះកណ្តាប់ដៃចុះមកលើតុ បង្កើតជាសូរសំឡេងព្រមានយ៉ាងខ្លាំងមួយផ្អើលមនុស្សគ្រប់គ្នា។

ក្រោមទឹកមុខដែលគ្របដោយរបាំងនៃកំហឹងនិងភាពអស់សង្ឃឹម គាត់បានខាំមាត់រំឭកពីកិច្ចកសាងអាណាចក្រអំណាចនិងលុយកាក់ តាំងពីគ្មានអ្វីសោះរហូតបានគ្រប់គ្រងគ្រប់ទិដ្ឋភាពនៃជីវិតក្នុងពិភពនៃក្តីស្រមៃ។ តែឥឡូវនេះនៅមានរឿងមួយដែលសំខាន់បំផុត គឺគ្រួសារ។ កូនស្រីសំណព្វចិត្តតែមួយ ត្រូវគេមកបំពាន់ចាប់យកទៅ អ្នកណាទប់ចិត្តបាន?

រំពេចនោះ ទ្វារចូលត្រូវបានគោះរន្ថើនហើយរបើកឡើងទាំងមិនទាន់ពោលអនុញ្ញាត។

ដាវីឌ ជាកូនប្រុសច្បងរបស់គាត់បានសម្រុកចូល ជាមួយទឹកមុខស្លេកដោយភាពតក់ស្លុត។

ដាវីឌបើកភ្នែកធំៗ ដោយភាពភ័យខ្លាចនិងមានសកម្មភាពសែនបន្ទាន់។

«ប៉ា!» សំឡេងរបស់ដាវីឌបានបង្កប់មកជាមួយនូវចិត្តខ្ទេចខ្ទាំ។ ដង្ហើមរបស់អភិជនវ័យ២៤ឆ្នាំបានរុះរោយពេញក្នុងទុក្ខសោក។

គេរត់ពេញបន្ទប់មករកឪពុកជាមួយថេប្លេតមួយយ៉ាងតឹងក្នុងដៃ។

«ប៉ាមើលនេះ!»

អគ្គនាយក ម៉ែនដា ងាកមើលមុខកូនប្រុសដោយស្រឡាំងកាំង។ ដាវីឌមិនខ្ជះខ្ជាយពេលវេលាជាមួយការពន្យល់ទេ។ គេបានអូសលើអេក្រង់កុំព្យូទ័របន្ទះ ហើយលើកវាឡើងឱ្យឪពុកមើល។

នៅលើអេក្រង់គឺជារូបភាពដ៏ឈឺចាប់មិនអាចបំភ្លេចបាន គឺដាវីនដែលអង្គុយលើគែមគ្រែក្នុងបន្ទប់ចម្លែក ដែលពួកគេមិនធ្លាប់ដឹងថា នៅឯណា ជារបស់អ្នកណា។

មុខរបស់នាងស្លេក រាងកាយរបស់នាងតឹងតែងក្នុងទុក្ខព្រួយ។ ប៉ុន្តែជានាងពិតៗ។ ទោះមើលទៅនាងនៅរស់និងមានសុវត្ថិភាពសម្រាប់ពេលនេះក៏មិនមែនបានន័យថា អាចធូរស្រាលចិត្តច្រើននោះដែរ។

ហើយបន្ទាប់មកមានស៊ីណានបង្ហាញមុខ។

ម៉ែនដាភ្ញាក់ព្រើត។

បុរសក្មេងម្នាក់ដំណាលដេវីឌ ដែលធ្លាប់តែដើរតាមពីក្រោយខ្លួន របៀបជានាយកម្នាក់ក្នុងចំណោមនាយកជាច្រើន ពេលនេះបានក្បត់គាត់ របៀបដ៏អាក្រក់បំផុត។

ស៊ីណានឈរក្រពាត់ដៃ នៅផ្ទៃខាងក្រោយនៃរូបភាព ជាមួយស្នាមញញឹមកាចសាហាវ។ ភ្នែករបស់អគ្គនាយក រេគិតបើកដោយការតក់ស្លុត។

«ស៊ីណាន? វាចង់បានលុយប៉ុន្មាន?»

គាត់វាចាដោយម៉ឺលៗព្រោះថាកំហឹងបានផ្ទុះឡើងបង្កប់សំឡេងរបស់គាត់ឱ្យតឹងណែន។

«អាតិរច្ឆាននោះ» ដេវីឌនិយាយទាំងងក់ក្បាលខឹង។ ដៃរបស់គេញាប់ញ័រ នៅពេលអូសដើម្បីបង្ហាញរូបភាពមួយទៀត នេះមកពីកាមេរ៉ាឃ្លាំមើលនៅខាងក្រៅអគារធនាគារ ដែលស៊ីណានទំនងបានបោកនាងដាវីនឱ្យចូលទៅក្នុងឡានរបស់គេហើយនាំចាកចេញតាមសម្រួល។

ភ្នែករបស់អគ្គនាយកងងឹតដោយក្តីមានះ ហើយដៃម្ខាងតោងជាប់នឹងចំហៀងតុ។

«វាចង់បានស្អី? ម្តេចវាហ៊ានប្រើកូនស្រីរបស់ខ្ញុំមកប្រឆាំងនឹងខ្ញុំ?!»

«យើងត្រូវធ្វើការឥឡូវនេះ រុករកកន្លែងវា!» ដាវីឌតឿន ។ លោក ម៉ែនដា ដើរពេញបន្ទប់ ចុះឡើងៗ ចិត្តរបស់គាត់លោតកញ្ជ្រោល បេះដូងនេះមានអារម្មណ៍ថាអាចនឹងផ្ទុះចេញពីទ្រូងបាន។ កូនស្រីរបស់គាត់...ជាវត្ថុមានតម្លៃបំផុតដែលម៉ែនដាមិនអាចបាត់បង់បានបែរជាពេលនេះមកធ្លាក់ក្នុងដៃបុរសម្នាក់ដែលដែលមិនដែលសង្ស័យនិងមិនអាចប៉ាន់ស្មានបំណងពិតប្រាកដបាន។

ដើរបានមួយជុំ អភិជនឈប់ភ្លាមៗ ហើយបែរមុខទៅកូនប្រុសជាមួយសំឡេងពេញដោយការតាំងចិត្ត និងកំហឹងយ៉ាងត្រជាក់៖

«យកប្អូនមកវិញ! ដោយមធ្យោបាយណាក្តី!»

គាត់ងាកទៅពួកជំនួយការ ហើយបន្ថែម៖

«ស៊ើបប្រវត្តិអាម្នាក់នោះឱ្យខ្ញុំ!»